# សាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា

## យុត្តិសាស្ត្ររបស់គណៈកម្មាធិការសិទ្ធិមនុស្ស
## នៃអង្គការសហប្រជាជាតិ
## បណ្តឹងលេខ ៤២៨/១៩៩០

CCPR/C/51/D/441/1990

**( សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ )**


បកប្រែដោយ៖ លោក ស្រ៊ាង ចិន្តា

កែសម្រួលដោយ៖ មាស បូរ៉ា

រចនាដោយ៖ អែម ចន្ទី



ឆ្នាំ ២០២១

# បណ្តឹងលេខ ៤៤១/១៩៩០

**ប្តឹងដោយ:** Robert Casanovas នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩០

**ជនរងគ្រោះត្រូវចោទ:** ដើមបណ្តឹង

**រដ្ឋភាគី:** ប្រទេសបារាំង

**ប្រកាសអាចទទួលយកបាន:** ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៩៣
(សម័យប្រជុំទី៤៨)

**កាលបរិច្ឆេទអនុម័តសេចក្តីសម្រេច:** ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤
(សម័យប្រជុំទី៥១)

**កម្មវត្ថុ:** ការពន្យារនៅក្នុងនីតិវិធីតុលាការរដ្ឋបាលលើបណ្តឹង ស្តីអំពីការបដិសេធពី សេវាសាធារណៈ។

**បញ្ហានីតិវិធី:** ប្រទេសបារាំង បានរក្សាសិទ្ធិមិនអនុវត្តមាត្រា៥(២)(ក) នៃពិធីសារបន្ថែម(មុនពេលមានការពិនិត្យមើលលើសំណុំរឿងនេះដោយគណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប) ស្តីពីភាពអាចទទួលយកបាន (*យុត្តាធិការតាមប្រធានបទ ratione materiae*)

**បញ្ហាសំខាន់:** បញ្ញត្តិ "វិស័យរដ្ឋប្បវេណី"(ការជំនុំជម្រះក្តីដោយយុត្តិធម៌) រយៈពេល នៃដំណើរការទៅតាមនីតិវិធីរបស់តុលាការ

**មាត្រា នៃកតិកាសញ្ញា:** មាត្រា២(៣)(ក) និង(ខ)ព្រមទាំងមាត្រា១៤(១)

**មាត្រា នៃពិធីសារបន្ថែម:** មាត្រា៣ និងមាត្រា៥(២)(ក)

១. ដើមបណ្តឹង នៃបណ្តឹងនេះ គឺ Robert Casanovas ជាពលរដ្ឋបារាំងរស់នៅក្នុងទីក្រុង Nancy។ គាត់អះអាងថា ខ្លួនជាជនរងគ្រោះ នៃការរំលោភមួយដោយប្រទេសបារាំង លើមាត្រា២ កថាខណ្ឌទី៣(ក) និង(ខ) ព្រមទាំងមាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

*អង្គហេតុដាក់មកដោយដើមបណ្តឹង*

**២.១** ដើមបណ្តឹង គឺជាអតីតសមាជិកកងពលតូច នៃនាយកដ្ឋានអគ្គិភ័យទីក្រុង Nancy។ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៨៧ គាត់ត្រូវបានតែងតាំងជាប្រធានមជ្ឈមណ្ឌល de Secours Principal of Nancy។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៨ គាត់ត្រូវបានបណ្តេញចេញដោយចោទថា គ្មានសមត្ថភាព ដោយសេចក្តីសម្រេចរបស់អាជ្ញាធរតំបន់ និងនាយកដ្ឋាន។ ដើមបណ្តឹងបានប្តឹងឧទ្ធរណ៍ទៅតុលាការរដ្ឋបាលទីក្រុង Nancy ដែលបានបដិសេធសេចក្តីសម្រេចនេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨៨។ លោក Casanovas ត្រូវបានចូលកាន់តំណែងរបស់គាត់វិញតាមសេក្តីសម្រេចចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៨៩។

**២.២** ប៉ុន្តែរដ្ឋបាលក្រុង បានចាប់ផ្តើមនីតិវិធីថ្មីប្រឆាំងនឹងដើមបណ្តឹង ដែលបានចេញជាលទ្ធផលនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៨៩។ ក្នុងសេចក្តីសម្រេចទី២ នេះបានបញ្ចប់ការងាររបស់គាត់។ ដើមបណ្តឹង បានជំទាស់នឹងសេចក្តីសម្រេចនេះ នៅមុខតុលាការរដ្ឋបាលទីក្រុង Nancy នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៨៩។ នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៨៩ ប្រធានតុលាការនេះបានបញ្ជា

ឱ្យបិទការស៊ើបអង្កេតបឋម។ តាមរយៈលិខិតមួយចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ លោក Casanovas បានស្នើទៅប្រធានតុលាការ ឱ្យដាក់សំណុំរឿងរបស់គាត់លើរបៀបវារៈ ដែលមុនគេតាមទៅអាចធ្វើបាន។ សំណើនេះ ត្រូវបានបញ្ជាក់ជាថ្មីនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៨៩ ។ តាមរយៈលិខិតចុះថ្ងៃទី១១ ខែមករា ឆ្នាំ១៩៩០ ប្រធានតុលាការបានជូនដំណឹងទៅគាត់ថា បញ្ហានេះមិនត្រូវបានពិនិត្យមើលជាបន្ទាន់ទេ និងថាសំណុំរឿងនេះនឹងត្រូវចុះបញ្ជីទៅតាមលំដាប់កាល។ ដោយហេតុថា គ្មានកាលៈទេសៈពិសេសទេ មានន័យថាសំណុំរឿងនេះនឹងមិនត្រូវបានជំនុំជម្រះក្នុងឆ្នាំ១៩៩០ឬ១៩៩១ ទេ។

**២.៣** នៅថ្ងៃទី២៣ ខែមករា និងម្តងទៀតនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ ១៩៩០ ដើមបណ្តឹងបានជូនដំណឹងទៅតុលាការ ដោយគាត់យល់ថា ការពន្យារពេលការជំនុំជម្រះបែបនេះ គឺជាការរំលោភមាត្រា៦ នៃកតិកាសញ្ញាអឺរ៉ុប ស្តីពីការការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ហេតុនេះ គាត់ក៏បានស្នើឱ្យចុះសំណុំរឿងរបស់គាត់លើប្រតិទិនតុលាការ ទៅតាមមាត្រា៥០៦ និង៥០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីបារាំង។ គាត់មិនបានទទួលការឆ្លើយតបជាថ្មីម្តងទៀត។ ហេតុនេះ គាត់ក៏បានស្នើទៅតុលាការ ឱ្យទទួលស្គាល់បង្កាន់ដៃ នៃដីកាសន្និ-ដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមុនគេរបស់គាត់។ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩០ តុលាការបានជូនដំណឹងទៅគាត់ថា គាត់មិនត្រូវបានគេរើសអើងទេ តែថាការពន្យារពេលការជំនុំជម្រះ ដោយសារតែមានសំណុំរឿងជាច្រើនតាំងពីឆ្នាំ១៩៨៦ មកម្លេះដែលត្រូវដោះស្រាយមុន។ ក្នុងកាលៈទេសៈនេះ តុលាការមិនអាចពិនិត្យមើលសំណុំរឿងរបស់ដើមបណ្តឹងមុនគេបានទេ ។

**២.៤** នៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩០ ដើមបណ្ដឹងបានស្នើទៅប្រធានតុលាការរដ្ឋបាលជាថ្មីម្ដងទៀត ឱ្យជំនុំជម្រះសំណុំរឿងរបស់គាត់។ សំណើនេះត្រូវបានបញ្ជាក់ជាថ្មីនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩០ តែត្រូវប្រធានតុលាការបដិសេធនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩០។

**២.៥** នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩០ លោក Casanovas បានដាក់ពាក្យប្ដឹងទៅគណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប ដោយបានលើកយកមាត្រា៦ នៃកតិកាសញ្ញាអឺរ៉ុប ស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានមកអះអាង។ តាមរយៈសេចក្ដីសម្រេចថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩០ គណៈកម្មការបានប្រកាសថា បណ្ដឹងរបស់គាត់ គឺមិនអាចទទួលយកបានទេ។ ដោយគណៈកម្មការពិនិត្យឃើញថា កតិកាសញ្ញានេះ មិនមានចែងអំពីនីតិវិធីលើបញ្ហាបណ្ដេញមន្ត្រីរាជការចេញពីការងារនោះទេ។

**២.៦** ចំពោះលក្ខខណ្ឌតម្រូវនៃការប្រើប្រាស់ដំណោះស្រាយក្នុងស្រុកឱ្យអស់លទ្ធភាព ដើមបណ្ដឹងបញ្ជាក់ថា គាត់អាចប្ដឹងទៅតុលាការបារាំងផ្សេងទៀតបាន លុះត្រាតែនិងរហូតដល់តុលាការរដ្ឋបាលក្រុង Nancy វិនិច្ឆ័យសំណុំរឿងរបស់គាត់ចប់សព្វគ្រប់សិន។ ហេតុដូច្នេះ គាត់យល់ឃើញថា គាត់បានបំពេញទៅតាមលក្ខខណ្ឌតម្រូវក្នុងមាត្រា៥ កថាខណ្ឌទី២(ខ) នៃពីធីសារបន្ថែមហើយ ។

*ការប្តឹង*

**៣.១** ដើមបណ្តឹង ប្តឹងថា រដ្ឋភាគីបានខកខានក្នុងការផ្តល់ឱ្យគាត់នូវ "ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព" ដោយសារតែការពន្យារពេលវិនិច្ឆ័យសំណុំរឿងរបស់គាត់យ៉ាងតិចណាស់បីឆ្នាំ។ ដើមបណ្តឹងអះអាងថា ការពន្យារពេលនេះ គឺគ្មានហេតុផលជាក់ស្តែង និងមិនអាចផ្តល់យុត្តិកម្ម ដោយសារតែការងារច្រើនរបស់តុលាការរដ្ឋបាលបានទេ។ ដើមបណ្តឹង លើកឡើងថា ខ្លួនមិនជឿថាតុលាការរដ្ឋបាលអាចវិនិច្ឆ័យករណីទីមួយរបស់ខ្លួន (ពាក់ព័ន្ធនឹងការបណ្តេញចេញក្នុងឆ្នាំ១៩៨៨) ក្នុងរយៈពេលប្រាំខែបានទេ។ រីឯបណ្តឹងទីពីររបស់គាត់ទំនងជានឹងត្រូវចំណាយពេលជាច្រើនឆ្នាំទៀត ក្នុងការវិនិច្ឆ័យជាមិនខាន។

**៣.២** ដើមបណ្តឹងបន្តប្តឹងទៀតថា រដ្ឋភាគីនៃកតិកាសញ្ញាមានកាតព្វកិច្ចផ្តល់នូវការជំនុំជម្រះរបស់ខ្លួនទៅតាមមធ្យោបាយចាំបាច់ ដើម្បីផ្តល់នូវភាពយុត្តិធម៌យ៉ាងមានប្រសិទ្ធភាព និងយ៉ាងរហ័ស។ យោងតាមដើមបណ្តឹង ការពន្យារពេលយ៉ាងតិចបីឆ្នាំនេះមិនមែនជាបញ្ហាទេ ប្រសិនបើសំណុំរឿងនេះត្រូវបានជំនុំជម្រះនៅសាលាដំបូង។ ដើមបណ្តឹងអះអាងទៀតថា ចំពោះការប្តឹងឧទ្ធរណ៍ទៅតុលាការឧទ្ធរណ៍រដ្ឋបាល និងការប្តឹងជាបន្តបន្ទាប់ទៅក្រុមប្រឹក្សាជាតិ គាត់គិតថា ការពន្យារពេលអាចមានរយៈប្រហែលពេល១០ឆ្នាំ។

**៣.៣** ដើមបណ្តឹងបន្តបញ្ជាក់ទៀតថា សំណុំរឿងមួយពាក់ព័ន្ធនឹងការបណ្តេញចេញពីការងាររាជការ គឺបញ្ហាបន្ទាន់មួយ។ នៅក្នុងបរិបទនេះ ដើម

បណ្តឹងបញ្ជាក់ថា គាត់មិនទទួលប្រាក់ខែតាំងពីថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៨៩ មកម្ល៉េះ។ គាត់អះអាងថា សេចក្តីសម្រេចបីឆ្នាំក្រោយ ទោះបីជាទៅតាមអ្វីដែលគាត់បានទាមទារក៏ដោយ ក៏វានឹងមិនមានប្រសិទ្ធភាពដែរ។ ជាងនេះទៅទៀត ដើមបណ្តឹងលើកឡើងថា ដោយប្រធាននៃអង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិក្នុងការដាក់សំណុំរឿងរបស់គាត់ក្នុងបញ្ជីនោះ គាត់អាចធ្វើទៅតាមសំណើរបស់ដើមបណ្តឹងយកសំណុំរឿងមកពិនិត្យមើលជាលក្ខណៈពិសេសបាន។

## *ព័ត៌មាន និងការពិនិត្យអង្កេត របស់រដ្ឋភាគីពាក់ព័ន្ធនឹងភាពអាចទួលយកបាន នៃ បណ្តឹងនេះ*

**៤.១** រដ្ឋភាគីបានលើកឡើងថា បណ្តឹងនេះមិនអាចទទួលយកបានទេ ពីព្រោះការរក្សាសិទ្ធិមិនអនុវត្ត ដែលបានធ្វើឡើងដោយរដ្ឋាភិបាលបារាំង តាមរយៈការដាក់តម្កល់លិខិតុបករណ៍ នៃការផ្តល់សច្ចាប័នលើពិធីសារបន្ថែម នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ តាមខ្លឹមសារមាត្រា៥ កថាខណ្ឌទី២(ក) គណៈកម្មាធិការសិទ្ធិមនុស្ស "មិនមានសមត្ថកិច្ចពិនិត្យមើលបណ្តឹងបុគ្គលទេ ប្រសិនបើបណ្តឹងដូចគ្នានេះ កំពុងត្រូវបានពិនិត្យ ឬត្រូវបានពិនិត្យរួចហើយ ក្រោមនីតិវិធីនៃការស៊ើបសួរឬដំណោះស្រាយអន្តរ-ជាតិផ្សេងទៀត"។

**៤.២** រដ្ឋភាគី បញ្ជាក់ថា ការរក្សាសិទ្ធិមិនអនុវត្ត អាចប្រើចំពោះករណីនេះបាន ពីព្រោះ ដើមបណ្តឹងធ្លាប់បានដាក់បណ្តឹងនេះទៅគណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបរួចហើយ ដែលត្រូវគណៈកម្មការនេះប្រកាសមិនអាចទទួលយកបាន។ រដ្ឋភាគីលើកឡើងថា អង្គហេតុដែលគណៈកម្មការអឺរ៉ុបសម្រេចមិនពិនិត្យមើលលើអង្គសេចក្តី គឺមិនបានប្រានចោលការអនុវត្ត នូវការរក្សាសិទ្ធិមិនអនុ-

វត្តនោះទេ ខណៈដែលករណីនេះពាក់ព័ន្ធនឹងបុគ្គលតែមួយ អង្គហេតុតែមួយ និងការអះអាងតែមួយ។ ក្នុងបរិបទនេះ រដ្ឋភាគីសំដៅទៅដល់សេចក្ដីសម្រេចរបស់គណៈកម្មាធិការពាក់ព័ន្ធនឹងបណ្ដឹង លេខ១៦៨/១៩៨៤ ដែលគណៈកម្មាធិការបានសម្រេចថា ឃ្លា"បញ្ហាដូចគ្នា សំដៅដល់ភាគីដូចគ្នា ចំពោះបណ្ដឹងទាំងឡាយដែលបានធ្វើឡើងនិងអង្គហេតុទាំងឡាយ ដែលបានលើកឡើងជាការគាំទ្រដល់បណ្ដឹងទាំងនោះ"។

**៤.៣** រដ្ឋភាគីបន្តលើកឡើងទៀតថា បណ្ដឹងនេះមិនអាចទទួលយកបាន ដោយសារខុសទៅនឹង*សមត្ថកិច្ចតាមប្រធានបទ ratione materiae*។ រដ្ឋភាគីលើកឡើងថា មាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញា មិនអាចយកមកអនុវត្តបានទេ ពីព្រោះនីតិវិធីនៅមុខតុលាការរដ្ឋបាល មិនពាក់ព័ន្ធទៅនឹង "សិទ្ធិ និងកាតព្វកិច្ចនៅក្នុងបណ្ដឹងទេ"។ ក្នុងបរិបទនេះ រដ្ឋភាគីសំដៅដល់សេចក្ដីសម្រេចរបស់គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប ដែលបានសម្រេចថា កតិកាសញ្ញាអឺរ៉ុប ស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មិនបានគ្របដណ្ដប់ទៅលើនីតិវិធី ក្នុងការបណ្ដេញចេញពីការងាររាជការទេ និងបានគូសបញ្ជាក់ថា ខ្លឹមសារដែលគណៈកម្មការអឺរ៉ុប បានយកធ្វើជាមូលដ្ឋាន នៃសេចក្ដីសម្រេចរបស់ខ្លួន គឺដូចគ្នាទៅនឹងខ្លឹមសារមាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញានេះដែរ។ លើសពីនេះទៅទៀត ខុសគ្នាពីមាត្រា៦ កថាខណ្ឌទី១ នៃកតិកាសញ្ញាអឺរ៉ុប មាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនបានចែងអំពីសិទ្ធិទទួលសេចក្ដីសម្រេចរបស់តុលាការក្នុងរយៈពេលសមស្របទេ។

**៤.៤** រដ្ឋភាគីបន្តលើកឡើងថា មាត្រា២ កថាខណ្ឌទី៣ នៃកតិកាសញ្ញា ដែលធានានូវដំណោះស្រាយប្រកបដោយប្រសិទ្ធភាពចំពោះបុគ្គលទាំងឡាយ

ដែលសិទ្ធិនិងសេរីភាព ដូចត្រូវបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា ត្រូវបានរំលោភបំពាន មិនត្រូវបានរំលោភបំពានឡើយ ដោយហេតុថា នីតិវិធីនៅមុខតុលាការរដ្ឋបាលអាចជាដំណោះស្រាយមួយដោយមានប្រសិទ្ធភាព។ យោងតាមរដ្ឋភាគី ការយល់ឃើញបែបនេះត្រូវបានបង្ហាញតាមរយៈសេចក្តីសម្រេចរបស់តុលាការរដ្ឋបាល ដែលបានបដិសេធនឹងការបណ្តេញដើមបណ្តឹងចេញពីការងារក្នុងខែធ្នូ ឆ្នាំ១៩៨៨។

## *សេចក្តីសម្រេចរបស់គណៈកម្មាធិការ លើភាពអាចទទួលយកបាន*

**៥.១** ក្នុងសម័យប្រជុំលើកទី៤៨ គណៈកម្មាធិការ បានពិនិត្យទៅលើភាពអាចទទួលយកបានបណ្តឹងនេះ។ គណៈកម្មាធិការ បានកត់សម្គាល់លើសេចក្តីពន្យល់របស់រដ្ឋភាគីថា បណ្តឹងនេះមិនអាចទទួលយកបាន ពីព្រោះតែការរក្សាសិទ្ធិមិនអនុវត្តមាត្រា៥ កថាខណ្ឌទី២ នៃពិធីសារបន្ថែមរបស់រដ្ឋភាគី។ គណៈកម្មាធិការពិនិត្យឃើញថា គណៈកម្មការអឺរ៉ុបបានប្រកាសពីភាពមិនអាចទទួលយកបាន នៃបណ្តឹងរបស់ដើមបណ្តឹង ដោយសារតែផ្ទុយទៅនឹងសមត្ថកិច្ចតាមប្រធានបទ ជាមួយនឹងកតិកាសញ្ញាអឺរ៉ុប។ គណៈកម្មាធិការ ពិនិត្យឃើញថា ដោយសិទ្ធិនៃកតិកាសញ្ញាអឺរ៉ុប បានធ្វើឱ្យមានភាពខុសគ្នានៅក្នុងសារធាតុពាក់ព័ន្ធទៅនឹងនីតិវិធី នៃការអនុវត្តន៍របស់ខ្លួន ជាមួយនឹងសិទ្ធិចែងនៅក្នុងកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ នៅក្នុងអត្ថន័យនៃការរក្សាសិទ្ធិមិនអនុវត្ត។ បញ្ហាដែលត្រូវបានប្រកាស ពីភាពមិនអាចទទួលយកបាន ដោយសារខុសនឹងសមត្ថកិច្ចតាមប្រធានបទ មិនត្រូវបានពិនិត្យឃើញទៅតាមរបៀបមួយដែលថា គណៈកម្មាធិការត្រូវបានដកចេញពីការពិនិត្យមើលសំណុំរឿងនោះទេ។

**៥.២** គណៈកម្មាធិការបានរំឭកថា បញ្ញត្តិ "វិស័យរដ្ឋប្បវេណី (suit at law)" ក្រោមមាត្រា១៤ កថាខណ្ឌទី១ បានផ្អែកទៅលើលក្ខណៈនៃសិទ្ធិ ដែលបង្កើតជាបញ្ហានេះ ជាជាងទៅលើស្ថានភាពរបស់ភាគីណាមួយ។ គណៈកម្មាធិការពិនិត្យឃើញថា នីតិវិធីមួយពាក់ព័ន្ធទៅនឹងការបណ្តេញចេញពីការងារ បានបង្កើតឱ្យមានការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចនៅក្នុងវិស័យរដ្ឋប្បវេណី ដែលស្ថិតនៅក្នុងខ្លឹមសារមាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញា។ ហេតុដូច្នេះ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៣ គណៈកម្មាធិការបានប្រកាសថា បណ្តឹងនេះអាចទទួលយកបាន។

## *ព័ត៌មានទទួលបាន បន្ទាប់ពីការប្រកាសពីភាពអាចទទួលយកបាន*

**៦.១** តាមរយៈលិខិតចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៤ ដើមបណ្តឹងបានជូនដំណឹងដល់គណៈកម្មាធិការថា តុលាការរដ្ឋបាលក្រុង Nancy នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩១ បានចេញសេចក្តីសម្រេចទៅតាមការស្នើសុំរបស់គាត់ និងថាគាត់ត្រូវតែបានចូលកាន់តំណែងរបស់ខ្លួនវិញ។ ទោះបីជាយ៉ាងណា គាត់បានបន្ថែមទៀតថា នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩២ រដ្ឋបាលក្រុងបានបញ្ចប់ការងាររបស់គាត់ជាឯកតោភាគី និងថា សេចក្តីសម្រេចនេះកំពុងស្ថិតនៅក្នុងតុលាការរដ្ឋបាលជាថ្មី។ គាត់បានបន្តបញ្ជាក់ទៀតថា ជម្លោះដែលចេះតែបន្តជាមួយនឹងផ្នែករដ្ឋបាល និងការពន្យារពេលដ៏យូរនៅក្នុងតុលាការ នាំឱ្យគាត់មានអារម្មណ៍ធុញថប់ និងធ្លាក់ទឹកចិត្តដោយសារតែមូលហេតុនេះ បានជាសុខភាពរបស់គាត់ចេះតែធ្ងន់ធ្ងរទៅៗ។

**៦.២** មិនមានព័ត៌មាន ឬការពិនិត្យអង្កេត ត្រូវបានបញ្ជូនមកដោយរដ្ឋភាគីនោះទេ ទោះបីជាមានការក្រើនរំឭកមួយបានផ្ញើទៅ នៅថ្ងៃទី០៣ ខែឧសភា

ឆ្នាំ១៩៩៤ ក៏ដោយ។ គណៈកម្មាធិការមានការសោកស្តាយ ដោយសារតែអវត្តមាននៃកិច្ចសហប្រតិបត្តិការរបស់រដ្ឋភាគី ព្រមទាំងបានរំឮកថា កិច្ចសហប្រតិបត្តិការនេះ មានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៤ កថាខណ្ឌទី២ នៃពិធីសារបន្ថែម ដែលរដ្ឋភាគីគួរតែផ្តល់ព័ត៌មាន ដែលអាចប្រើប្រាស់បានទាំងអស់របស់ខ្លួនមកគណៈកម្មាធិការ។ ក្នុងកាលៈទេសៈនេះទម្ងន់ដ៏សមរម្យ ត្រូវបានផ្តល់ទៅឱ្យការចោទប្រកាន់របស់ដើមបណ្តឹង ទៅតាមវិសាលភាព ដែលដើមបណ្តឹងបានបង្ហាញភស្តុតាង។

## *ការពិនិត្យមើលទៅលើអង្គសេចក្តី*

**៧.១** គណៈកម្មាធិការសិទ្ធិមនុស្ស បានពិនិត្យមើលលើបណ្តឹងនេះ ដោយផ្អែកទៅលើព័ត៌មាន ដែលបានផ្តល់មកដោយភាគី ដូចមានចែងនៅក្នុងមាត្រា៥ កថាខណ្ឌទី១ នៃពិធីសារបន្ថែម។

**៧.២** គណៈកម្មាធិការកត់សំគាល់ថា បញ្ហាចោទចំពោះមុខខ្លួន ថាតើរយៈពេលនៃនីតិវិធីនៅមុខតុលាការរដ្ឋបាល Nancy ពាក់ព័ន្ធនឹងការបណ្តេញចេញលើកទី២ ក្នុងថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៨៩ បានបំពានសិទ្ធិទទួលបានការវិនិច្ឆ័យសេចក្តីប្រកបដោយយុត្តិធម៌ ក្នុងខ្លឹមសារនៃមាត្រា១៤(១) នៃកតិកាសញ្ញាដែរឬទេ?

**៧.៣** *គណៈកម្មាធិការរំឮកថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ក្រោមមាត្រា១៤ កថាខណ្ឌទី១ ត្រូវមានលក្ខខណ្ឌតម្រូវមួយចំនួន រួមទាំងលក្ខខណ្ឌ ដែលតម្រូវឱ្យនីតិវិធីនៅមុខតុលាការ ត្រូវតែបានធ្វើឡើងយ៉ាងរហ័ស។* គណៈកម្មាធិការកត់សម្គាល់ឃើញថា ក្នុងសំណុំរឿងនេះនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៨៩ ដើមបណ្តឹងបានដាក់ប្តឹងប្រឆាំងនឹងការបណ្តេញពីការងារ

របស់គាត់ នៅមុខតុលាការរដ្ឋបាលក្រុង Nancy និងឃើញថា តុលាការនោះ បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានលើការស៊ើបអង្កេតបឋម នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៨៩ ក៏បានចេញសាលក្រមរបស់ខ្លួនលើសំណុំរឿងនេះ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩១។

**៧.៤** គណៈកម្មាធិការកត់សម្គាល់ឃើញថា ដើមបណ្តឹងបានទទួលនូវសេចក្តីសម្រេចទៅតាមការទាមទាររបស់ខ្លួនពីតុលាការរដ្ឋបាលក្រុង Nancy ហើយគាត់ត្រូវបានចូលកាន់តំណែងរបស់ខ្លួនជាថ្មី។ គួរចងចាំថា អង្គហេតុដែលតុលាការត្រូវពិនិត្យមើល ថាតើសំណុំរឿងរបស់ដើមបណ្តឹងមានអាទិភាពជាងរឿងសំណុំផ្សេងទៀតឬទេ គឺគណៈកម្មាធិការរកឃើញថា អំឡុងពេលដែលបានកន្លងផុតទៅ ចាប់ពីពេលចេញដីកាសន្និដ្ឋានបញ្ជូនបណ្តឹង ស្តីពីការបណ្តេញចេញខុសប្រក្រតីឱ្យស៊ើបសួររហូតដល់ពេលចេញសេចក្តីសម្រេចឱ្យចូលកាន់តំណែងជាថ្មី មិនបានបង្កើតឱ្យមានការរំលោភមាត្រា១៤ កថាខណ្ឌទី១ នៃកតិកាសញ្ញាទេ។

**៨.** ក្រោមមាត្រា៥ កថាខណ្ឌទី៤ នៃពីធីសារបន្ថែម លើកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ គណៈកម្មាធិការយល់ឃើញថា អង្គហេតុនៅចំពោះមុខខ្លួន មិនបានបង្ហាញឱ្យឃើញនូវការរំលោភណាមួយទៅលើបទប្បញ្ញត្តិ នៃកតិកាសញ្ញានេះទេ។